## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
## តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# យុទ្ធសាស្ត្រ

# ស្តីពី

# ការប្រាស្រ័យទាក់ទង

## ផែនការអនុវត្តរយៈពេលបីឆ្នាំ (ផអ៣) នៃកម្មវិធីជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ខែមិថុនា ឆ្នាំ២០១៧

រៀបចំ និងបោះពុម្ពដោយ៖ លេខាធិការដ្ឋាន គ.ជ.អ.ប

# អារម្ភកថា

ផ្អែកលើមូលដ្ឋានគ្រឹះ ដែលបានបង្កើតឡើងក្នុងអំឡុងពេលនៃផែនការអនុវត្តដំណាក់កាលដំបូង (ផអ៣ទី១) ផែនការអនុវត្ត៣ឆ្នាំ ដំណាក់កាលទី២ (ផអ៣ទី២) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានកំណត់នូវវិធីសាស្ត្រថ្មីសម្រាប់ជំរុញការធ្វើវិមជ្ឈការឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ដោយផ្ដោតជាសំខាន់ទៅលើការផ្ទេរសិទ្ធិអំណាច មុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព តម្លាភាព និងគណនេយ្យភាព។ ដើម្បីជានាដល់ការសម្រេចបាននូវគោលបំណងនេះ តម្រូវឱ្យមានការកែទម្រង់ផ្ទៃក្នុងស្ថាប័នរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមាន ការកែសម្រួលតួនាទីភារកិច្ច និងការទទួលខុសត្រូវ ការកែសម្រួលនូវរបៀបរបបនិងនីតិវិធីប្រតិបត្តិការងារ និងការផ្លាស់ប្ដូរនូវឥរិយាបថរបស់មន្ត្រី បុគ្គលិកនៃក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ការធ្វើឱ្យមានភាពល្អប្រសើរឡើងក្នុងការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានឱ្យបានទូលំទូលាយ និងទាន់ពេលវេលាអំពីចក្ខុវិស័យ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជូនដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា គឺជាកត្តាដ៏មានសារៈសំខាន់សម្រាប់ជំរុញការកែទម្រង់ផ្ទៃក្នុងស្ថាប័នទាំងនេះ។

ក្នុងន័យនេះ យុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទងនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍមធ្យោបាយ និងវិធីសាស្ត្របែបទំនើបសម្រាប់កែលម្អការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានក្នុងក្របខ័ណ្ឌនៃការអនុវត្ត ផអ៣ រវាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាឱ្យកាន់តែមានប្រសិទ្ធភាព។

យុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទងនេះ បរិយាយអំពីសមាសភាគសំខាន់ៗចំនួន៥ដែលត្រូវរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ សមាសភាគ

ទាំង៥នេះ រួមមាន ១).ការបង្កើតឧបករណ៍ទំនាក់ទំនងសំខាន់ៗ ២).ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង ៣).ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងបែបទំនើប ៤).ការផ្សព្វផ្សាយទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង៥).ការចូលរួមរបស់ប្រជាពលរដ្ឋ។

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងនេះ នឹងប្រើប្រាស់បណ្តាញបច្ចេកវិទ្យាព័ត៌មានដែលកំពុងមានការរីកចម្រើន ជាពិសេសនឹងប្រើប្រាស់កម្មវិធីថ្មីៗនៃបណ្តាញទំនាក់ទំនងសង្គម ដែលកំពុងពេញនិយមសម្រាប់ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានទាន់ហេតុការណ៍នានាពាក់ព័ន្ធនឹងការវិវត្ត បញ្ហាប្រឈម និងវិធានការដែលត្រូវផ្តោតការយកចិត្តទុកដាក់ដោះស្រាយ ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុកនានា នៃផអ៣។

គ.ជ.អ.ប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមមតិយោបល់ និងអនុសាសន៍របស់តំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចដំណើរការរៀបចំយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងនេះ។

គ.ជ.អ.ប សង្ឃឹមជឿជាក់យ៉ាងមុតមាំថា ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា នឹងសហការគ្នាអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងនេះប្រកបដោយប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


រូប ..................................................................................... v
តារាង .................................................................................. v
អក្សរកាត់ ............................................................................. vi
សេចក្ដីផ្ដើម ............................................................................ 1
តើយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទងមានន័យដូចម្ដេច? .................... 2
វិសាលភាពនៃយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង ............................ 3
ស្ថានភាពបច្ចុប្បន្ន ..................................................................... 3
ទស្សនវិស័យ និងគោលបំណង ........................................................ 6
១. សមាសភាគទី១៖ ឧបករណ៍ទំនាក់ទំនងសំខាន់ៗ ................................. 8
១.១ សនិទានភាព ........................................................................ 8
១.២ គោលបំណង ........................................................................ 8
១.៣ លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត ............ 8
១.៤ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ ............................... 13
២. សមាសភាគទី២៖ ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង .................. 14
២.១ សនិទានភាព ....................................................................... 14
២.២ គោលបំណង ....................................................................... 14
២.៣ តួនាទី ភារកិច្ចមន្ត្រីការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន... 15
២.៤ ការឆ្លើយតបតម្រូវការព័ត៌មានតាមក្រុមគោលដៅ .......................... 17
២.៥ ភាពជាដៃគូ ........................................................................ 18
២.៦ លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត ........... 18
៣.សមាសភាគទី៣៖ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប ...................................................................... 21

៣.១ សនិទានភាព.......................................................................... 21
៣.២ គោលបំណង.......................................................................... 21
៣.៣ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ............................. 21
៣.៤ បណ្តាញទំនាក់ទំនងសង្គម (ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប)...........22
៣.៥ លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត ...........23
៤.សមាសភាគទី៤៖ ការផ្សព្វផ្សាយទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ......................................................................25
៤.១ សនិទានភាព .........................................................................25
៤.២ គោលបំណង..........................................................................25
៤.៣ លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត ...........26
៥. សមាសភាគទី៥៖ ការចូលរួមរបស់ប្រជាពលរដ្ឋ.................................29
៥.១ សនិទានភាព..........................................................................29
៥.២ គោលបំណង..........................................................................30
៥.៣ អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការផ្តល់សេវា (ការអនុវត្តមុខងារ) ដែលបានផ្ទេរ.................................30
៥.៣.១ គោលបំណង.......................................................................30
៥.៣.២ ពេលវេលា ........................................................................30
៥.៣.៣ ក្រុមគោលដៅ .................................................................... 31
៥.៣.៤ ចំណុចសំខាន់ដែលត្រូវបង្ហាញ............................................ 31
៥.៣.៥ បណ្តាញផ្សព្វផ្សាយ..............................................................32
៥.៤ អនុវត្តការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រដើម្បីជំរុញការផ្ទេរមុខងារ.... ..........................................................................................34
៥.៥ លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត............35
៦. ផែនការសកម្មភាព និងថវិកា .........................................................37

## រូប

រូបទី១៖ ការប្រាស្រ័យទាក់ទងនៃ ផអ៣ទី២ ........................................ 1
រូបទី២៖ គំរូនៃការប្រាស្រ័យទាក់ទង ........................................ 3
រូបទី៣៖ ក្រុមគោលដៅ ........................................ 5

## តារាង

តារាងទី១៖ លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត សម្រាប់ការរៀបចំបង្កើតឧបករណ៍ទំនាក់ទំនង ........................................ 9
តារាងទី២៖លក្ខខណ្ឌការងារនៃការិយាល័យទំនាក់ទំនង និង ផ្សព្វផ្សាយព័ត៌មាន ........................................ 15
តារាងទី៣៖ លទ្ធផលរំពឹងទុកសំខាន់ៗសកម្មភាព ពេលវេលា និង ស្ថាប័នអនុវត្ត សម្រាប់ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង ........................................ 18
តារាងទី៤៖ លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត សម្រាប់ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប ........................................ 23
តារាងទី៥៖ លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត សម្រាប់ការផ្សព្វផ្សាយ ទស្សនវិស័យនៃកំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការ ........................................ 26
តារាងទី៦៖ យុទ្ធនាការផ្សព្វផ្សាយ ដែលមានសក្តានុពលក្នុងការធ្វើឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងផលប្រយោជន៍របស់ប្រព័ន្ធផ្សព្វផ្សាយ.... ........................................ 32
តារាងទី៧៖ លទ្ធផលរំពឹងទុកសំខាន់ៗ សម្រាប់យុទ្ធនាការដែលមានការចូលរួមពីប្រជាពលរដ្ឋ ........................................ 35
តារាងទី៨៖ ផែនការសកម្មភាពប្រាស្រ័យទាក់ទងសង្ខេប ........................................ 37

## អក្សរកាត់

| អក្សរកាត់ | បរិយាយ |
|---|---|
| គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផអ៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# សេចក្តីផ្តើម

ឯកសារនេះរៀបរាប់អំពីវិធីសាស្ត្រ នៃការប្រាស្រ័យទាក់ទងសម្រាប់អនុវត្តផែនការអនុវត្តរយៈពេលបីឆ្នាំ (ផអ៣) នៃកម្មវិធីជាតិដែលមានគោលបំណងប្រែក្លាយរបៀបរបបនៃការអនុវត្តការប្រាស្រ័យទាក់ទងដើម្បី៖

- ផ្សារភ្ជាប់យ៉ាងច្បាស់លាស់ទៅនឹងគោលបំណងជាយុទ្ធសាស្ត្រ នៃផអ៣។
- ធ្វើឱ្យមានភាពកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរឥរិយាបថរបស់ក្រុមគោលដៅ។
- បំពេញតម្រូវការរបស់ក្រុមគោលដៅឱ្យបានកាន់តែល្អប្រសើរជាងមុន។
- ធ្វើឱ្យមានការប្រើប្រាស់កាន់តែទូលំទូលាយនូវមធ្យោបាយប្រាស្រ័យទាក់ទង។

ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងដើម្បីឆ្លើយតបទៅនឹងគោលបំណងទាំងនេះ។

យុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្តសម្រាប់ផអ៣នៃកម្មវិធីជាតិ ដែល

**រូបទី១៖ ការប្រាស្រ័យទាក់ទងនៃផអ៣ទី២**

- យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង គឺផ្តោតលើ "ការចែករំលែកព័ត៌មានក្នុងចំណោមស្ថាប័នរដ្ឋ និងរវាងស្ថាប័នរដ្ឋជាមួយសាធារណជន ក្នុងគោលបំណងផ្តល់ព័ត៌មានសំខាន់ៗ ឱ្យបានច្បាស់លាស់ និងកំណត់អំពីវិធីសាស្ត្រសមស្របសម្រាប់ផ្តល់ព័ត៌មានដល់ក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នា (ទំព័រ២៥)។
- ចក្ខុវិស័យនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើការពិនិត្យឡើងវិញដើម្បីធ្វើការកែសម្រួលនូវបែបផែននៃការផ្តល់ព័ត៌មាន ព្រមទាំងការរៀបចំបង្កើតឧបករណ៍ មធ្យោបាយ និងសម្ភារៈសម្រាប់ផ្សព្វផ្សាយព័ត៌មាន ឱ្យមានលក្ខណៈសាមញ្ញដល់ក្រុមអ្នកពាក់ព័ន្ធជាក់លាក់នានា ក្នុងគោលបំណងលើកកម្ពស់នូវគំនិតផ្តួចផ្តើមប្រកបដោយភាពម្ចាស់ការនៅគ្រប់កម្រិត។ ជាមួយគ្នានេះដែរ វិធីសាស្ត្រផ្សព្វផ្សាយព័ត៌មានដ៏មានប្រសិទ្ធភាពមួយត្រូវបានរៀបចំឡើង និងត្រូវអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា (ទំព័រ២៥)។

> ផអ៣ទី២នឹង "កែលម្អការប្រាស្រ័យទាក់ទងព័ត៌មាន និងបង្កើនការយល់ដឹងតាមរយៈការប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងព័ត៌មាន ដើម្បីផ្លាស់ប្តូរឥរិយាបថធ្វើឱ្យមានភាពកាន់តែច្បាស់លាស់អំពីចក្ខុវិស័យនៃកំណែទម្រង់ កែលម្អលំហូរនៃព័ត៌មានរវាងស្ថាប័នអនុវត្តកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្តល់ឱកាសឱ្យអង្គការសង្គមស៊ីវិលបានចូលរួមកាន់តែច្រើន" (ទំព័រ១០៤)។

រៀបរាប់អំពីដំណើរការនៃការកែសម្រួលមធ្យោបាយប្រាស្រ័យទាក់ទងដែលមាននាពេលបច្ចុប្បន្ន ឱ្យក្លាយទៅជាមធ្យោបាយប្រាស្រ័យទាក់ទង ដែលកាន់តែមានលក្ខណៈជាយុទ្ធសាស្ត្រ និងទំនើប។ ការកែសម្រួលនេះនឹងជួយឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប មានមធ្យោបាយប្រាស្រ័យទាក់ទងកាន់តែល្អប្រសើរ ដើម្បីជំរុញឱ្យអ្នកពាក់ព័ន្ធនានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចូលរួមក្នុងកិច្ចដំណើរការកំណែទម្រង់ និងជានាដល់ការឆ្លើយតបទៅនឹងគោលបំណងដែលបានកំណត់ក្នុងផអ៣ (សូមមើលរូបទី១)។

## តើយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងមានន័យដូចម្តេច?

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង គឺជាដំណើរការនេះ៖

- ការប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទង ដើម្បីសម្រេចគោលដៅដែលមានលក្ខណៈច្បាស់លាស់ និងពិតប្រាកដ ដែលពាក់ព័ន្ធទៅនឹងការកែលម្អឥរិយាបថរបស់បុគ្គល និងការប្រព្រឹត្តទៅរបស់ស្ថាប័នដោយផ្អែកលើ និងឆ្លើយតបទៅនឹងព័ត៌មានទទួលបាន។ លើសពីនេះទៀត ការរៀបចំផលិតសារត្រូវមានលក្ខណៈសាមញ្ញ ងាយយល់ និងងាយស្រួលប្រើប្រាស់ដោយអ្នកពាក់ព័ន្ធ។
- ការរៀបចំព័ត៌មានផ្សព្វផ្សាយ តាមរយៈមធ្យោបាយនានាដែលសមស្របទៅនឹងស្ថានភាព និងកម្រិតយល់ដឹងរបស់ក្រុមគោលដៅ។

## វិសាលភាពនៃយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង

យុទ្ធសាស្ត្រនេះត្រូវបានរំពឹងថានឹងមានការវិវត្តបន្តិចម្ដងៗ ទៅតាមពេលវេលា។ ទោះយ៉ាងនេះក្ដី យុទ្ធសាស្ត្រនេះមិនគ្របដណ្ដប់លើ៖

១).ដំណើរការបណ្ដុះបណ្ដាល ទោះបីជា ការបណ្ដុះបណ្ដាល ត្រូវបានប្រើជាញឹកញាប់ ធ្វើជាមធ្យោបាយប្រាស្រ័យទាក់ទង អំពីកំណែទម្រង់ក៏ដោយ។

២).យន្តការរៀនសូត្រ និងផ្ដល់យោបល់ត្រឡប់ ជាពិសេសពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងយោបល់ត្រឡប់ អំពីការបំពេញតួនាទី ភារកិច្ចរបស់បុគ្គលិក ដែលជាផ្នែកមួយនៃមុខងារគ្រប់គ្រងធនធានមនុស្ស។

## ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ននេះការប្រាស្រ័យទាក់ទងផ្ដោតលើការផ្សព្វផ្សាយព័ត៌មាន ដោយយកការបណ្ដុះបណ្ដាល ជាមធ្យោបាយសំខាន់សម្រាប់ការផ្លាស់ប្ដូរ និងចែករំលែកព័ត៌មានពីគ្នាទៅវិញទៅមករវាង

**រូបទី២៖ គំរូនៃការប្រាស្រ័យទាក់ទង**




- **បណ្ដាញ** គឺជាមធ្យោបាយ ឬប្រព័ន្ធផ្សព្វផ្សាយសម្រាប់បញ្ជូនសារ។ ការប្រើបណ្ដាញ នៃការប្រាស្រ័យទាក់ទងចម្រុះ អាចជួយឱ្យសារបានទៅដល់ក្រុមគោលដៅ។
- **សារ** គឺមានលក្ខណៈសាមញ្ញ ហើយច្បាស់លាស់ ដែលអ្នករៀបចំសារចង់ប្រាប់អំពីការងាររបស់ពួកគេ។ សារដែលបង្កើតឡើងបានល្អរួមមាន៖ ១).ផ្សារភ្ជាប់ទៅនឹងគោលបំណងរបស់ស្ថាប័ន ២).ច្បាស់ ហើយសាមញ្ញ ៣). ចង្អុលបង្ហាញ "ការអំពាវនាវឱ្យមានសកម្មភាព" ដូចជា របៀបទាក់ទាញក្រុមគោលដៅ ជំរុញពួកគេឱ្យធ្វើសកម្មភាព

ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបណ្តុះបណ្តាលភាគច្រើនផ្តោតទៅលើ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌនៃការអនុវត្ត ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមច្បាប់ សេចក្តីណែនាំ ឬនីតិវិធីថ្មីៗដែលបានកំណត់ និងដាក់ឱ្យអនុវត្តពីថ្នាក់ជាតិ។ សារសោមញ្ញៗងាយយល់ពុំសូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពនានារបស់លេខាធិការ-ដ្ឋាន គ.ជ.អ.ប ឡើយ រួមទាំងវគ្គបណ្តុះបណ្តាលនានាផងដែរ។ ទោះបីជា គ.ជ.អ.ប មានគេហទំព័ររបស់ខ្លួនក៏ដោយ ក៏ប៉ុន្តែការចែករំលែកព័ត៌មានតាមរយៈបណ្តាញទំនាក់ទំនងសង្គមនាពេលបច្ចុប្បន្ននៅមានកម្រិតនៅឡើយ ក្នុងការប្រើប្រាស់ និងចែករំលែកព័ត៌មានពាក់ព័ន្ធនឹងកំណែទម្រង់។

> ៤).ចាត់អាទិភាព បង្ហាញពីចំណុចជាក់លាក់ដែលមានប្រយោជន៍ដល់អ្នកដទៃ។ **សារ** អាចជារូបភាព ការដកស្រង់សម្តី និងទិន្នន័យផ្សេងៗទៀត។
>
> - **ក្រុមគោលដៅ** គឺជាអ្នកដែលត្រូវប្រាស្រ័យទាក់ទងហើយចាប់អារម្មណ៍លើសារ។ ក្រុមគោលដៅខ្លះ គឺសំខាន់ជាងក្រុមគោលដៅដទៃទៀត។ ជាទូទៅការប្រាស្រ័យទាក់ទងមានបំណងកែប្រែឥរិយាបថរបស់ក្រុមគោលដៅ។
> - **លទ្ធផល** គឺជាអ្វីដែលយើងចង់សម្រេចបាន។ ជាធម្មតា គឺជាការកែប្រែឥរិយាបថ ឬសកម្មភាពរបស់ក្រុមគោលដៅ។

ទាក់ទងទៅនឹងក្រុមគោលដៅ ការប្រាស្រ័យទាក់ទងអាចធ្វើឡើងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬប្រជាពលរដ្ឋ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏អាចធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយផ្ទាល់ ឬដោយអនុវត្តយុទ្ធនាការ ប្រាស្រ័យទាក់ទងក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប (រូបទី៣)។

**រូបទី៣៖ ក្រុមគោលដៅ**




ការប្រាស្រ័យទាក់ទងនៅក្នុងជួររាជរដ្ឋាភិបាល ដោយចេញពីលេខាធិការដ្ឋាន គ.ជ.អ.ប ទៅកាន់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិជាទូទៅ ត្រូវបានចាត់ទុកថាជាការប្រាស្រ័យទាក់ទងផ្ទៃក្នុង រីឯការប្រាស្រ័យទាក់ទងចេញពីលេខាធិការដ្ឋាន គ.ជ.អ.ប ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅកាន់ប្រជាពលរដ្ឋត្រូវបានចាត់ទុកថាជាការប្រាស្រ័យទាក់ទងខាងក្រៅ។

បច្ចុប្បន្ននេះ ការយល់ដឹងស៊ីជម្រៅ អំពីចរិតលក្ខណៈរបស់ក្រុមគោលដៅសំខាន់ៗ ដូចជាឥរិយាបថ មតិយោបល់ និងអាកប្បកិរិយា របស់ក្រុមគោលដៅនៅតាមក្រសួង ស្ថាប័ន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានកម្រិតនៅឡើយ។ ការយល់ដឹងនៅមានកម្រិត នេះជះឥទ្ធិពលដល់ការរៀបចំសារ ឬព័ត៌មាននានា។

ជាទូទៅ សារ ឬព័ត៌មាននានាដែលបាន និងកំពុងប្រើប្រាស់នាពេលនេះ នៅមានលក្ខណៈស្មុគស្មាញ។ ដើម្បីធានាឱ្យមានប្រសិទ្ធភាពកាន់តែល្អប្រសើរឡើង

ក្នុងការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មាន សារ ឬព័ត៌មានទាំងនោះ គួរគប្បីរៀបចំឱ្យមានលក្ខណៈសាមញ្ញជាងនេះ និងងាយស្រួលប្រើប្រាស់ ហើយត្រូវសរសេរជាភាសាសាមញ្ញ ដែលក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ឬប្រជាពលរដ្ឋទូទៅងាយយល់។

ការប្រាស្រ័យទាក់ទង គឺជាជំនាញចាំបាច់មួយដែលត្រូវប្រើប្រាស់ដោយក្រសួង ស្ថាប័នអនុវត្តផអ៣ ទាំងអស់។ នៅពេលអនាគត លេខាធិការដ្ឋាន គ.ជ.អ.ប នឹងដើរតួនាទីកាន់តែសំខាន់ក្នុងការផ្តល់អនុសាសន៍ដល់ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគោលដៅកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ទស្សនវិស័យ និងគោលបំណង

ទស្សនវិស័យទូទៅ៖

> ការប្រាស្រ័យទាក់ទងដែលមានឥទ្ធិពលទៅលើអ្នកពាក់ព័ន្ធសំខាន់ៗ ប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានគោលបំណងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានទូលំទូលាយ ការឆ្លើយតបទៅនឹងតម្រូវការនានា ការយល់ដឹងពីគោលគំនិតរបស់ក្រុមគោលដៅ និងការប្រើប្រាស់បច្ចេកវិទ្យាបែបទំនើប។

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើនេះ យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងចែកចេញជា **៥សមាសភាគ** និងគោលបំណង ដូចខាងក្រោម៖

| សមាសភាគ | លទ្ធផលរំពឹងទុក/គោលបំណង |
|---|---|
| **១.ឧបករណ៍ទំនាក់ទំនងសំខាន់ៗ** | ការបង្កើតឧបករណ៍ទំនាក់ទំនងសំខាន់ៗ |

| | |
|---|---|
| | ដែលអាចប្រើប្រាស់ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងសមស្របទៅតាមស្ថានភាពជាក់ស្តែងនានាយ៉ាងទូលំទូលាយ |
| **២.ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង** | លេខាធិការដ្ឋាន គ.ជ.អ.ប មានសមត្ថភាពអនុវត្តវិធីសាស្ត្រការប្រាស្រ័យទាក់ទងដែលមានលក្ខណៈជាយុទ្ធសាស្ត្រ |
| **៣.ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប** | ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើបចូលរួមគាំទ្រ និងបង្កើនការយល់ដឹងអំពីកំណែទម្រង់ |
| **៤.ការផ្សព្វផ្សាយទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធមានការយល់ដឹង និងចូលរួមលើកកម្ពស់កំណែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ |
| **៥.ការចូលរួមរបស់ប្រជាពលរដ្ឋ** | ប្រជាពលរដ្ឋមានការយល់ដឹងអំពីការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាជាក់លាក់នានា និងសារៈសំខាន់នៃការផ្ទេរមុខងារទាំងនោះ ព្រមទាំងចូលរួមក្នុងយន្តការផ្តល់យោបល់ត្រឡប់ ដើម្បីកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ |

ផ្នែកបន្ទាប់នឹងរៀបរាប់អំពីសមាសភាគនីមួយៗនៃយុទ្ធសាស្ត្រ ស្តីពីការប្រាស្រ័យទាក់ទង៖

# សមាសភាគ ទី១. ឧបករណ៍ទំនាក់ទំនងសំខាន់ៗ

## ១.១. សនិទានភាព

ដើម្បីធ្វើឱ្យការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពចាំបាច់ ត្រូវមានឧបករណ៍ទំនាក់ទំនងសំខាន់ៗ ដែលមានសង្គតិភាពក្នុងការប្រើប្រាស់។ ឧបករណ៍ទំនាក់ទំនងសំខាន់ៗទាំងនេះអាចលើកកម្ពស់កិត្តិនាមរបស់ស្ថាប័ន រួមទាំងប្រជាប្រិយភាពក្នុងការគ្រប់គ្រង និងប្រសិទ្ធភាពការងាររបស់ស្ថាប័នទាំងនោះផងដែរ។ ជាទូទៅការរៀបចំឱ្យមានប្រព័ន្ធ និងយន្តការនៃការប្រាស្រ័យទាក់ទងនឹងជួយឱ្យចំណេញពេលវេលា។ ទន្ទឹមគ្នានេះ ការបង្កើតឧបករណ៍ទំនាក់ទំនងដែលអាចប្រើប្រាស់តាមវិធីសាស្ត្រផ្សេងៗគ្នាប្រកបដោយភាពងាយស្រួល និងមានប្រសិទ្ធភាពជាមួយក្រុមគោលដៅ នឹងអាចធានាបាននូវសង្គតិភាពនៃសារ ព្រមទាំងអាចងាយស្រួលក្នុងការធ្វើបច្ចុប្បន្នភាពទៅតាមតម្រូវការចាំបាច់នានា។

## ១.២. គោលបំណង

ការរៀបចំឧបករណ៍ទំនាក់ទំនងសំខាន់ៗសម្រាប់ប្រើប្រាស់ និងយកមកអនុវត្តឱ្យមានប្រសិទ្ធភាព និងសមស្របទៅតាមស្ថានភាព។

## ១.៣. លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត

ដើម្បីធានាដល់ការបង្កើតបាននូវឧបករណ៍ទំនាក់ទំនងសំខាន់ៗ ត្រូវផ្តោតទៅលើលទ្ធផលរំពឹងទុកចំនួន០៤ តាមរយៈការអនុវត្តនូវសកម្មភាពសំខាន់ទៅតាមក្របខ័ណ្ឌពេលវេលា ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

## តារាងទី១៖
## លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត សម្រាប់ការរៀបចំបង្កើតឧបករណ៍ទំនាក់ទំនង

| ល.រ | លទ្ធផលរំពឹងទុក និងសកម្មភាព | ពេលវេលា និង ស្ថាប័នអនុវត្ត |
| --- | --- | --- |
| គោលបំណង៖ ការបង្កើតឧបករណ៍ទំនាក់ទំនងសំខាន់ៗដែលអាចប្រើប្រាស់ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងសមស្របទៅតាមស្ថានភាពជាក់ស្តែង | | |
| **លទ្ធផលរំពឹងទុក ១.៣.១** | **ឧបករណ៍ទំនាក់ទំនង ដោយមានឈ្មោះ/រូបសញ្ញាសម្គាល់ គ.ជ.អ.ប ត្រូវបានរៀបចំបង្កើត**<br>• រៀបចំសារច្បាស់លាស់ ងាយយល់ដែលអាចប្រើប្រាស់បានដោយអ្នកពាក់ព័ន្ធនានា។ សារ ឬព័ត៌មានដែលត្រូវបានផ្តួចផ្តើមឡើងមាននៅក្នុងផ្នែកទី២ នៃយុទ្ធសាស្ត្រនេះ (សេចក្តីណែនាំ ផ្នែកទី២)។<br>• រៀបចំសន្លឹកព័ត៌មានខ្លីៗអំពីកិច្ចការសំខាន់ៗមួយចំនួនដូចជា ការផ្ទេរមុខងារ មូលនិធិក្រុង ស្រុក អាណត្តិទូទៅរបស់ក្រុមប្រឹក្សា ការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ និងអំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>• រៀបចំសេចក្តីណែនាំស្តីពីការបង្កើតនិមិត្តសញ្ញា និងពាក្យស្លោកខ្លីៗងាយយល់អំពី គ.ជ.អ.ប។<br>• បង្កើតទម្រង់រួមដោយមានរូបសញ្ញា គ.ជ.អ.ប សម្រាប់ប្រើប្រាស់នៅក្នុងការធ្វើបទបង្ហាញនានា។ | • ឆ្នាំ២០១៧<br>• លេខាធិការដ្ឋាន គ.ជ.អ.ប |

| | | |
|---|---|---|
| | • បង្កើតសម្ភារៈដូចជា ផ្ទាំងបដាចល័ត[1] សម្រាប់ប្រើប្រាស់ក្នុងព្រឹត្តិការណ៍នានា ការធ្វើទស្សនកិច្ច ការតាំងនៅបន្ទប់ប្រជុំ និងកន្លែងទទួលភ្ញៀវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។<br>• រៀបចំករណីសិក្សាដែលបង្ហាញពីជោគជ័យនៃកិច្ចសហការរវាងអង្គភាពនានានៃលេខាធិការដ្ឋាន គ.ជ.អ.ប រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។<br>• ចងក្រងកម្រងសំណួរដែលសួរញឹកញាប់ជាងគេ (FAQs) នៅលើគេហទំព័រ និងឧបករណ៍ទំនាក់ទំនង។<br>• អនុវត្តសាកល្បងឧបករណ៍ខាងលើជាមួយក្រុមគោលដៅដើម្បីធានាឱ្យមានការចាប់អារម្មណ៍របស់ក្រុមគោលដៅទាំងនោះ។<br>• បង្កើតប្រវត្តិរូបសង្ខេបខ្លីៗរបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកសំខាន់ៗ ដើម្បីដាក់ក្នុងគេហទំព័ររបស់ គ.ជ.អ.ប និងឧបករណ៍ទំនាក់ទំនង។<br>• ប្រើប្រាស់កម្មវិធីកុំព្យូទ័រ (ដូចជា MS Access Excel ឬកម្មវិធីឥតគិតថ្លៃ ដូចជា Mail chimp) ដើម្បីរៀបចំបញ្ជីឈ្មោះទំនាក់ទំនងសម្រាប់ព្រឹត្តិបត្រព័ត៌មាន និងព័ត៌មានផ្សេងទៀត។<br>• បង្កើតទម្រង់ចុះឈ្មោះតាមរយៈ អ៊ីម៉ែលនៅលើគេហទំព័រ ដើម្បីទទួលបានព័ត៌មានខ្លីៗ និងព្រឹត្តិបត្រព័ត៌មានដោយ | |

[1] សូមមើល http://www.popupstands.co.uk/shop/pro-roller-banner/

| | | |
|---|---|---|
| | មានតំណរភ្ជាប់ដែលអាចទាញយកបានឯកសារបោះពុម្ពផ្សាយនានា ឱកាសអាចចូលរួមព្រឹត្តិការណ៍ ការមើលបទបង្ហាញតាមអ៊ីនធឺណេត ។ល។<br>• បង្កើតទម្រង់សេចក្តីប្រកាសព័ត៌មាន។<br>• ពិនិត្យឡើងវិញលើមធ្យោបាយផ្សព្វផ្សាយ (ដូចជាគេហទំព័រ ព្រឹត្តិបត្រព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមនានា) ឱ្យស្របទៅតាមគោលបំណងរបស់ គ.ជ.អ.ប។<br>• ជារៀងរាល់ឆ្នាំ ត្រូវកំណត់យកពេលមួយខែ (ឧទាហរណ៍ ខែមីនា) ដើម្បីបង្កើនឧបករណ៍ទំនាក់ទំនងសំខាន់ៗបន្ថែមទៀត។ | |
| **លទ្ធផលរំពឹងទុក ១.៣.២** | **សេចក្តីណែនាំសម្រាប់ការប្រាស្រ័យទាក់ទងរបស់អង្គភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នអនុវត្តផអ៣ ត្រូវបានរៀបចំបង្កើត៖**<br>• ការតម្រូវឱ្យមានរៀបចំប័ណ្ណផ្សព្វផ្សាយព័ត៌មាន ដែលរៀបរាប់សង្ខេបអំពីសារ ឬព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់សម្រាប់ចែកជូនអ្នកចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាពាក់ព័ន្ធនានា។<br>• ការរៀបចំដំណើរការស្ទង់មតិអំពីការប្រាស្រ័យទាក់ទង និងឧបករណ៍ទំនាក់ទំនងសំខាន់ៗ ដើម្បីកែលម្អប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទង និងកែលម្អឧបករណ៍ទំនាក់ទំនងឱ្យកាន់តែមានភាពងាយយល់ និងងាយប្រើប្រាស់ដោយក្រុមគោលដៅ។ | • ឆ្នាំ២០១៧<br>• លេខាធិការដ្ឋាន គ.ជ.អ.ប |
| **លទ្ធផលរំពឹងទុក ១.៣.៣** | **បង្កើតបណ្តុំរូបភាព និងក្រាហ្វិកព័ត៌មានដែលមានគុណភាពខ្ពស់** | • ឆ្នាំ២០១៧<br>• ក្រុមហ៊ុនឯកជន<br>• ថវិកា៖ ១៥.០០០ |

| | | |
|---|---|---|
| | • រៀបចំបណ្តុំរូបភាពសម្រាប់ផ្សព្វផ្សាយសារ ឬព័ត៌មានសំខាន់ៗរបស់ គ.ជ.អ.ប ដែលពាក់ព័ន្ធនឹងសកម្មភាពសំខាន់ៗនៅមូលដ្ឋាន ហើយរូបថតទាំងនោះបង្ហាញពីអត្ថន័យដែលងាយយល់[2]។<br>• ជំរុញការប្រើប្រាស់ក្រាហ្វិក ឬផែនទីដែលជួយពន្យល់អំពីខ្លឹមសារដែលពិបាកយល់។<br>• បញ្ចូលរូបភាពទៅក្នុងគេហទំព័រ តាមបណ្តាញទំនាក់ទំនងសង្គម។ល។ | ដុល្លារ |
| **លទ្ធផលរំពឹងទុក ១.៣.៤** | **កែលម្អគេហទំព័រ គ.ជ.អ.ប ឱ្យប្រសើរឡើង**<br>• ពិនិត្យ និងកែលម្អគេហទំព័រ គ.ជ.អ.ប ឱ្យកាន់តែមានភាពងាយយល់ មិនសាំញ៉ាំ និងមានភាពទាក់ទាញដល់អ្នកប្រើប្រាស់ ព្រមទាំងអាចប្រើប្រាស់បានតាមទូរស័ព្ទទំនើប និងឧបករណ៍អេឡិចត្រូនិកផ្សេងៗទៀត។<br>• ដាក់បញ្ចូលនូវព័ត៌មានសំខាន់ៗនានា ដូចជា ករណីសិក្សា សំណួរដែលសួរញឹកញាប់ជាងគេ និងចំណងជើងឯកសារ។<br>• កែលម្អបាម៉ឺនុយ (Menu) ដោយត្រូវមានពាក្យបំព្រួញសម្រាប់ចូលទៅទំព័រសំខាន់ៗសម្រាប់អ្នកប្រើប្រាស់។<br>• ធ្វើការផ្សព្វផ្សាយគេហទំព័រនេះឱ្យបានទូលំទូលាយ។ | • ឆ្នាំ២០១៧<br>• លេខាធិការដ្ឋាន គ.ជ.អ.ប |

[2] ឧទាហរណ៍ - សូមមើលគេហទំព័រ https://cambodia.savethechildren.net/news/children-demand-lower-stunting-rates-race-survival និង គេហទំព័រ http://www.bbc.co.uk/mediaaction/where-we-work/asia/cambodia/loy9

## ១.៨. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ

ការបង្កើតឧបករណ៍ប្រាស្រ័យទាក់ទងដ៏ល្អ គឺគ្រាន់តែជាចំណុចចាប់ផ្តើមតែប៉ុណ្ណោះ។

ឧបករណ៍ទាំងនេះត្រូវភ្ជាប់ទៅនឹងសកម្មភាពប្រាស្រ័យទាក់ទង ដែលបានបញ្ជាក់នៅក្នុង សមាសភាគទី២៖ ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង សមាសភាគទី៣៖ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប សមាសភាគទី៤៖ ការផ្សព្វផ្សាយទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងសមាសភាគទី៥៖ ការចូលរួមរបស់ប្រជាពលរដ្ឋ។ អាស្រ័យហេតុនេះ ហានិភ័យនៃការអនុវត្តសមាសភាគនេះ គឺការចំណាយពេលវេលា និងកិច្ចខិតខំប្រឹងប្រែងជាច្រើនដែលស្ថិតនៅក្រៅក្របខ័ណ្ឌនៃលទ្ធផលរំពឹងទុករបស់ផអ៣។ ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ ត្រូវកំណត់យកកាលបរិច្ឆេទជាក់លាក់មួយ ឧទាហរណ៍៖ ក្នុងខែមីនា ឆ្នាំ២០១៧ ដើម្បីរៀបចំបង្កើតឧបករណ៍ទំនាក់ទំនង (ដឹកនាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប)។ ជារៀងរាល់ឆ្នាំ ត្រូវកំណត់យករយៈពេលមួយខែ ដើម្បីបង្កើនឧបករណ៍ទំនាក់ទំនងថ្មីបន្ថែមទៀត។

# សមាសភាគ ទី២. ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង

## ២.១. សនិទានភាព៖

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប គឺជាស្ថាប័នដែលមានសក្តានុពលក្នុងការអនុវត្តសកម្មភាពប្រាស្រ័យទាក់ទងបានយ៉ាងល្អប្រសើរ ក៏ប៉ុន្តែលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវការបន្តពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួនបន្ថែមទៀត។

## ២.២. គោលបំណង៖

ពង្រឹងសមត្ថភាពរបស់មន្ត្រីការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការផ្តួចផ្តើមអនុវត្តការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព។

ល័ក្ខខ័ណ្ឌការងារបច្ចុប្បន្នរបស់មន្ត្រីការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប គឺផ្តោតតែទៅលើការផ្តល់ព័ត៌មាន ជាជាងអនុវត្តនូវយុទ្ធសាស្ត្រនានាដែលជំរុញ និងគាំទ្រដល់ការសម្រេចបាននូវគោលបំណង និងការកែប្រែឥរិយាបទរបស់អ្នកពាក់ព័ន្ធនានាដូចដែលមានចែងក្នុងផអពទី២។ វិធីសាស្ត្រសំខាន់ចំនួន៣ នឹងត្រូវអនុវត្តដើម្បីពង្រឹងសមត្ថភាពមន្ត្រីការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន៖ ១).កែសម្រួលឡើងវិញនូវល័ក្ខខ័ណ្ឌការងារ និងមន្ត្រីនៃការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ២).រៀបចំវិធីសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងដែលផ្តោតទៅលើក្រុមគោលដៅជាក់លាក់ ៣).សហការ និងបង្កើនភាពជាដៃគូដើម្បីអភិវឌ្ឍសមត្ថភាព និងអនុវត្តសកម្មភាពប្រាស្រ័យទាក់ទង។

## តារាងទី២៖
## ល័ក្ខខ័ណ្ឌការងារនៃការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

| បច្ចុប្បន្ន | អនាគត |
|---|---|
| • បង្កើតប្រព័ន្ធដើម្បីរក្សាទុកឯកសារ និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងក្របខ័ណ្ឌគតិយុត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តកម្មវិធីជាតិ។ | • រៀបចំ និងអនុវត្តសកម្មភាពប្រាស្រ័យទាក់ទងដើម្បីធានាថាក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ មានការយល់ដឹងទូលំទូលាយអំពីគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងវឌ្ឍនភាពនានា។<br>• រៀបចំ និងអនុវត្តសកម្មភាពប្រាស្រ័យទាក់ទងដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងសកម្មភាពឃោសនាផ្សព្វផ្សាយ ដែលអាចធ្វើឱ្យកែប្រែឥរិយាបថអ្នកពាក់-ព័ន្ធ ឱ្យមានការយល់ដឹង និងគាំទ្រគោលបំណងដាក់លាក់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។<br>• អភិវឌ្ឍសមត្ថភាពក្រសួង ស្ថាប័នអនុវត្តផអព និងរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីការប្រាស្រ័យទាក់ទង។ |

ចំណាំ៖ ការកែសម្រួលល័ក្ខខ័ណ្ឌការងារជាផ្លូវការត្រូវធ្វើឡើងនៅក្នុងការធ្វើវិសោធន-កម្មប្រកាស។

### ២.៣. តួនាទី ភារកិច្ចមន្ត្រីការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន៖

ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាព តម្រូវឱ្យមានការបែងចែកឡើងវិញនូវការទទួលខុសត្រូវ ឱ្យបានច្បាស់លាស់រវាងបណ្ណាល័យ និងការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ការងារផ្តល់ព័ត៌មាន និងឯកសារត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បណ្ណាល័យ។ មន្ត្រីនៃការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានត្រូវផ្តោត

តែទៅលើគំនិតផ្តួចផ្តើមលើការងារប្រាស្រ័យទាក់ទង ដែលមានលក្ខណៈជាយុទ្ធសាស្រ្ត។ ក្នុងរយៈពេលវែង ប្រសិនបើលទ្ធផលនៃការអនុវត្តសកម្មភាពការប្រាស្រ័យទាក់ទងត្រូវបានបង្ហាញយ៉ាងច្បាស់ថា ជាមធ្យោបាយមួយដែលមានប្រសិទ្ធភាពក្នុងការចូលរួមសម្រេចបាននូវគោលបំណងរបស់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នោះចំនួនមន្ត្រី បុគ្គលិក និងទីប្រឹក្សាគួរត្រូវបានជ្រើសរើសបន្ថែមទៀត ដូចខាងក្រោម៖

| **ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន** | **បណ្ណាល័យ** |
|---|---|
| **ទទួលខុសត្រូវលើយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទង**<br>• ប្រធានការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន<br>• អនុប្រធានការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន (០៣រូប)<br>• ទីប្រឹក្សាទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន (០១រូប)<br>• មន្ត្រីទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន (០៣រូប)<br>• បុគ្គលិកគ្រប់គ្រងគេហទំព័រ (០១រូប)<br>• កម្មសិក្សាការី (០២រូប) | **ទទួលខុសត្រូវផ្តល់ និងចែកផ្សាយព័ត៌មាន**<br>• នាយិកាបណ្ណាល័យ/មន្ត្រីផ្តល់ព័ត៌មានជាន់ខ្ពស់ (០១រូប)<br>• មន្ត្រីជំនួយការព័ត៌មានវិទ្យា (០១រូប)<br>• បណ្ណារក្ស(០១រូប) |

ដើម្បីអនុវត្តកិច្ចការនេះ ល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក ទីប្រឹក្សា នឹងត្រូវកែសម្រួល ហើយកម្មសិក្សាការីនឹងត្រូវជ្រើសរើសដើម្បីបង្កើតបណ្តាញ និង

ធ្វើកិច្ចការជាក់លាក់។ ឧទាហរណ៍៖ ការគ្រប់គ្រងគេហទំព័រ ការសរសេរអត្ថបទព័ត៌មាន និងរៀបចំរក្សាទុកឯកសារ។ល។

## ២.៤. ការឆ្លើយតបតម្រូវការព័ត៌មានតាមក្រុមគោលដៅ៖

ការផ្តល់ព័ត៌មានគួរធ្វើឡើងនៅពេលមានការស្នើសុំ ហើយបណ្ណាល័យនឹងត្រូវឆ្លើយតបតាមតម្រូវការព័ត៌មានរបស់ក្រុមគោលដៅ ក្នុងគោលបំណងពង្រឹងការចូលរួម និងការឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ក្នុងគោលបំណងដើម្បី៖

- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្តល់ព័ត៌មាន ការណែនាំតម្រង់ទិសដល់អ្នកស្វែងរកព័ត៌មាន និងធ្វើឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ក្លាយជាស្ថាប័នដែលមានការទទួលខុសត្រូវខ្ពស់ក្នុងការឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ។
- ដោះស្រាយបញ្ហាទៅតាមវិធីដែលមានប្រសិទ្ធភាពស្របតាមគោលនយោបាយនៃកំណែទម្រង់។
- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មាន។
- សម្របសម្រួលការផ្តល់ព័ត៌មានដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានល្អប្រសើរ។
- កត់ត្រាការស្នើសុំ និងជូនដំណឹងដល់ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ដើម្បីកាត់បន្ថយបញ្ហាដែលកើតឡើង ដើម្បីផ្តល់ព័ត៌មានឱ្យបានល្អប្រសើរជាងមុន។
- ចងក្រងរក្សាទុកឯកសារ លិខិតបទដ្ឋានគតិយុត្ត និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

នៅក្នុងផ្នែកទី២នៃយុទ្ធសាស្ត្រនេះ (សេចក្តីណែនាំ ផ្នែកទី៤) មានពិពណ៌នាអំពីធាតុសំខាន់សម្រាប់ការផ្តល់ព័ត៌មាន រួមមាន៖ ១). ខ្សែទូរស័ព្ទពិសេស (Hotline) របស់បណ្ណាល័យ និងមានបុគ្គលិករួសរាយរាក់ទាក់ដែលអាចជួយផ្តល់ព័ត៌មានតាមការស្នើសុំ ២). រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នអាចទំនាក់ទំនងតាមទូរស័ព្ទ ឬផ្ញើសារស្នើរកព័ត៌មាន ៣). ការឆ្លើយតបឱ្យបានទាន់ពេលវេលា និងកំណត់កាលបរិច្ឆេទជាក់លាក់។

## ២.៥. ភាពជាដៃគូ៖

ការបង្កើតភាពជាដៃគូ ត្រូវបានចាត់ទុកជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង។ ភាពជាដៃគូអាចផ្តោតលើការអភិវឌ្ឍសមត្ថភាព។ ឧទាហរណ៍៖ ការបង្ហាត់បង្ហាញ ឬការអនុវត្តរួមគ្នានូវសកម្មភាព ឬកម្មវិធីទំនាក់ទំនងផ្សេងៗ។ ការអនុវត្តរួមគ្នាអាចផ្តល់ផលចំណេញខាងហិរញ្ញវត្ថុ (ឧទាហរណ៍៖ ថវិកាបដិភាគ) ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពដោយរៀនបណ្តើរធ្វើបណ្តើរ។ ចំណុចសំខាន់ៗអំពីលទ្ធភាពនៃភាពជាដៃគូមានរៀបរាប់នៅក្នុងផ្នែកទី៥នៃសេចក្តីណែនាំ។

## ២.៦.លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត

**តារាងទី៣៖**

**លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្តសម្រាប់ការអភិវឌ្ឍសមត្ថភាពប្រាស្រ័យទាក់ទង**

| ល.រ | លទ្ធផលរំពឹងទុក និងសកម្មភាព | ពេលវេលា និង ស្ថាប័នអនុវត្ត |
|---|---|---|
| គោលបំណង៖ | | |

| ពង្រឹងសមត្ថភាពការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីឱ្យការិយាល័យនេះអាចផ្តួចផ្តើមអនុវត្តការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព។ | | |
|---|---|---|
| លទ្ធផលរំពឹងទុក ២.៦.១ | **តួនាទី ភារកិច្ចការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានត្រូវបានកែសម្រួលឡើងវិញ និងចំនួនបុគ្គលិក ត្រូវបានបង្កើនបន្ថែម**<br>• ពិនិត្យឡើងវិញនិងកែសម្រួលនូវល័ក្ខខ័ណ្ឌការងារដើម្បីប្រគល់តួនាទីភារកិច្ចដល់មន្ត្រីជាក់លាក់ឱ្យទទួលខុសត្រូវចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងទំនាក់ទំនងជាមួយសារព័ត៌មាន។<br>• ពិនិត្យឡើងវិញ និងកែសម្រួលនូវល័ក្ខខ័ណ្ឌការងាររបស់ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ដើម្បីផ្ទេរការងារផ្សព្វផ្សាយព័ត៌មានទៅឱ្យបណ្ណាល័យ។<br>• ជួលទីប្រឹក្សាទំនាក់ទំនងចំនួន០១រូប។<br>• ជ្រើសរើសកម្មសិក្សាការីផ្នែកទំនាក់ទំនងឱ្យចូលធ្វើការ ក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ។ | • ខែមីនា ឆ្នាំ២០១៧<br>• លេខាធិការដ្ឋាន គ.ជ.អ.ប<br>• ថវិកា៖ $0 |
| លទ្ធផលរំពឹងទុក ២.៦.២ | **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដល់ក្រុមគោលដៅត្រូវបានបង្កើត**<br>ប្រព័ន្ធនេះរៀបរាប់លម្អិតនៅក្នុងផ្នែកទី៤នៃសេចក្តីណែនាំ។<br>• បង្កើត និងផ្សព្វផ្សាយខ្សែទូរស័ព្ទពិសេសដែលអាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហៅ | • ខែមីនា ២០១៧<br>• លេខាធិការដ្ឋាន គ.ជ.អ.ប<br>• ថវិកា៖ $0<br>• លទ្ធផល៖ យ៉ាងហោចណាស់ បានឆ្លើយតប ១០សំណួរក្នុងរយៈពេល |

| | | |
|---|---|---|
| | ទូរស័ព្ទចូល ហើយបុគ្គលិកបណ្ណាល័យ ហៅទូរស័ព្ទត្រឡប់ទៅវិញដើម្បីកាត់បន្ថយការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើតម្លៃសេវាទូរស័ព្ទ (ឧទាហរណ៍៖ ជានាឱ្យមានការឆ្លើយតបឆាប់រហ័ស)។<br>• ផ្សព្វផ្សាយខ្សែទូរស័ព្ទពិសេសតាមរយៈបណ្ណាល័យអេឡិចត្រូនិច និងគេហទំព័រ គ.ជ.អ.ប។ | ១ថ្ងៃនៃថ្ងៃធ្វើការក្នុង ១ខែ។ |
| **លទ្ធផលរំពឹងទុក ២.៦.៣** | **ភាពជាដៃគូយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាព និងអនុវត្តសកម្មភាពប្រាស្រ័យទាក់ទងរួមត្រូវបានបង្កើត**<br>ចំណុចនេះមានរៀបរាប់លម្អិត នៅក្នុងផ្នែកទី៥ នៃសេចក្តីណែនាំ។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងសហការ ជាមួយដៃគូដែលមានសក្តានុពលដោយផ្តោតលើការធ្វើការងាររួមគ្នា ការអភិវឌ្ឍសមត្ថភាព ការកសាងបណ្តាញ ការផ្តល់ហិរញ្ញវត្ថុរួម និងផ្នែកផ្សេងៗដែលផ្តល់ផលប្រយោជន៍រួម។ | • ឆ្នាំ ២០១៧-២០១៩<br>• លេខាធិការដ្ឋាន គ.ជ.អ.ប<br>• ថវិកា៖ $0<br>• លទ្ធផល៖លេខាធិការ-ដ្ឋាន គ.ជ.អ.ប ត្រូវចុះកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្រយ៉ាងហោចណាស់ចំនួន១ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០១៧ តទៅ។ |

# សមាសភាគ ទី៣. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និង ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប

## ៣.១. សនិទានភាព

ការចូលរួមរបស់អ្នកដឹកនាំនៅក្នុងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន គឺជាកត្តាដ៏មានសារៈសំខាន់។ ថ្នាក់ដឹកនាំគឺជាតំណាងស្ថាប័ន និងអាចលើកកម្ពស់ទស្សន-វិស័យ និងគោលបំណងរបស់ស្ថាប័ន។ នៅក្នុងយុទ្ធសាស្ត្រនេះអ្នកដឹកនាំនឹងប្រើប្រាស់បណ្តាញផ្សព្វផ្សាយចំនួន០២៖ (១)ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និង (២)ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប។

## ៣.២.គោលបំណង៖

បង្កើនការគាំទ្រ និងពង្រឹងការយល់ដឹងអំពីកំណែទម្រង់វិមជ្ឍការ និងវិសហមជ្ឍការ តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប។

## ៣.៣ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី

ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ដែលមានលក្ខណៈជាការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក រួមមាន៖

- ការអភិវឌ្ឍសមត្ថភាពបុគ្គលិក គ.ជ.អ.ប ឱ្យមានលទ្ធភាពក្នុងការចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដើម្បីផ្សព្វផ្សាយព័ត៌មានដែលមានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវអំពីកំណែទម្រង់។ អាស្រ័យដោយហេតុថា **វិទ្យុ** គឺជាប្រព័ន្ធផ្សព្វផ្សាយដែលមានប្រជាប្រិយភាព និងមានសារប្រយោជន៍ ដូច្នេះ លេខាធិការដ្ឋាន គ.ជ.អ.ប ចាំបាច់ត្រូវពង្រឹងសមត្ថភាពមន្ត្រី០១រូប ឬ០២រូប ដែលមានសំឡេងល្អ រួសរាយ និងមាន

ភាពជឿជាក់សម្រាប់និយាយតាមវិទ្យុ ធ្វើបទសម្ភាសន៍ និងចូលរួមក្នុងកម្មវិធីសន្ទនាតាមទូរស័ព្ទជាដើម។

- ការរៀបចំខ្លឹមសារព័ត៌មានសង្ខេបសំខាន់ៗ សម្រាប់ផ្តល់ជូនមន្ត្រីជាន់ខ្ពស់ក្នុងការចូលរួមក្នុងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសំខាន់ និងមានប្រជាប្រិយនានា។ ការចូលរួមនេះមានគោលបំណងដើម្បីជានាឱ្យប្រព័ន្ធផ្សព្វផ្សាយមានការយល់ដឹងស៊ីជម្រៅអំពីកិច្ចដំណើរការ និងសារៈប្រយោជន៍នៃកំណែទម្រង់ និងជំរុញឱ្យមានការផ្សព្វផ្សាយវិចារណកថាអំពី គ.ជ.អ.ប រួមមានព័ត៌មានខ្លីៗ ករណីសិក្សា សុន្ទរកថាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ល។ ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ត្រូវមានទំនុកចិត្តខ្ពស់ក្នុងការចូលរួមតាមកម្មវិធីទូរទស្សន៍ ឬផ្តល់បទសម្ភាសន៍ជាមួយកាសែត និងវិទ្យុនានា។

### ៣.៤ បណ្តាញទំនាក់ទំនងសង្គម (ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប)

ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដូចជា Facebook, Telegram, WhatsApp... អាចបង្កើតទំនាក់ទំនងថ្មីរវាងរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ បណ្តាញទំនាក់ទំនងនេះអាចលើកកម្ពស់ការប្រាស្រ័យទាក់ទងទៅវិញទៅមក និងជានាឱ្យស្ថាប័នអនុវត្តផអ៣ មានការចូលរួម និងមានឥទ្ធិពលទៅលើអ្នកពាក់ព័ន្ធផ្សេងទៀត។ ការចូលរួមរបស់ថ្នាក់ដឹកនាំក្នុងការប្រើប្រាស់បណ្តាញសង្គមទាំងនេះនឹងជួយជំរុញលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមនានាជួយផ្សព្វផ្សាយព័ត៌មានសំខាន់ៗនានា។ លើសពីនេះ បណ្តាញទំនាក់ទំនងសង្គមក៏អាចផ្សព្វផ្សាយព័ត៌មានទៅដល់អ្នកពាក់ព័ន្ធនានា ដែលមានការចាប់អារម្មណ៍អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងអាចផ្តល់ជាយន្តការក្នុងការទទួលយកនូវមតិ យោបល់ និងធ្វើការឆ្លើយតបចំពោះពួកគេវិញផងដែរ។

## ៣.៥.លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត

**តារាងទី៤៖**

**លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្តសម្រាប់ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើប**

| ល.រ | លទ្ធផលរំពឹងទុក និងសកម្មភាព | ពេលវេលា និង ស្ថាប័នអនុវត្ត |
|---|---|---|
| គោលបំណង៖<br>ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើបជួយបង្កើនការគាំទ្រ និងពង្រឹងការយល់ដឹងដល់សាធារណជនអំពីកំណែទម្រង់<br>**លទ្ធផល៖** ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់មន្ត្រីរាជរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋត្រូវបានពង្រឹង។ | | |
| លទ្ធផលរំពឹងទុក ៣.៥.១ | **បង្កើត និងអនុវត្តកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ**<br>• អភិវឌ្ឍសមត្ថភាពមន្ត្រីជាន់ខ្ពស់២រូបនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានសំឡេងល្អរួសរាយ និងមានភាពជឿជាក់សម្រាប់និយាយតាមវិទ្យុ ធ្វើបទសម្ភាសន៍ និងកម្មវិធីសន្ទនាតាមទូរស័ព្ទជាដើម។<br>• សម្របសម្រួលការធ្វើបទសម្ភាសន៍ និងការផ្សព្វផ្សាយរបស់មន្ត្រីជាន់ខ្ពស់ជាមួយទូរទស្សន៍ និងកាសែតជាប្រចាំ។ | • ខែមីនា ២០១៧<br>• ដៃគូអនុវត្តន៍<br>• ថវិកា៖ $0<br>• លទ្ធផល៖ យ៉ាងហោចណាស់ មន្ត្រីជាន់ខ្ពស់ ០២រូប ត្រូវបានសម្របសម្រួលឱ្យចូលរួមក្នុងកម្មវិធីប្រព័ន្ធផ្សព្វ-ផ្សាយ។ |
| លទ្ធផលរំពឹងទុក ៣.៥.២ | **បង្កើតនិងប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដែលជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងមន្ត្រីរាជរដ្ឋាភិបាល** | • ខែមីនាឆ្នាំ២០១៧<br>• ទីប្រឹក្សារយៈពេលខ្លី<br>• ថវិកា៖ $២០.០០០ |

| | | |
|---|---|---|
| | • រៀបចំល័ក្ខខ័ណ្ឌការងារ និងជួលទីប្រឹក្សារយៈពេលខ្លី០១រូប ដើម្បីបង្កើតទំព័រហ្វេសប៊ុក និងបណ្ដាញទំនាក់ទំនងសង្គមផ្សេងទៀត។<br>• កំណត់គោលបំណង និងគោលដៅនៃបណ្ដាញទំនាក់ទំនងសង្គម។<br>• កំណត់យកបណ្ដាញទំនាក់ទំនងសង្គមណាមួយដែលពេញនិយមបំផុត (ជម្រើសចំណុចខ្លាំង និងចំណុចខ្សោយ) ពិនិត្យឡើងវិញនូវបណ្ដាញទំនាក់ទំនងសង្គមដែលក្រសួងផ្សេងទៀតបានប្រើប្រាស់។<br>• កំណត់ក្រុមគោលដៅ និងអ្វីដែលពួកគេចង់បាននៅក្នុងយុទ្ធនាការបណ្ដាញទំនាក់ទំនងសង្គម។<br>• បង្កើតទំព័រហ្វេសប៊ុក (ឬទំព័រសមស្របផ្សេងទៀត)ដោយពិនិត្យមើលអ្នកប្រើប្រាស់ ដើម្បីធានាថាទំព័រនេះទំនងជាអាចផ្ដល់ផលប្រយោជន៍ដល់ពួកគេ។<br>• រៀបចំកាលវិភាគផ្សព្វផ្សាយអំពីសកម្ម-ភាព នៅលើបណ្ដាញទំនាក់ទំនងសង្គម (ឧទាហរណ៍៖ ពេលណាត្រូវដាក់រូបថត ពេលណាត្រូវដាក់ព័ត៌មានក្នុងប្លក់(Blog)។<br>• វាយតម្លៃប្រសិទ្ធភាពនៃការចូលរួមរបស់បណ្ដាញទំនាក់ទំនងសង្គម។ | • លទ្ធផល៖ យ៉ាងហោចណាស់អ្នកប្រើហ្វេស-ប៊ុកសកម្ម មានចំនួន ១.០០០នាក់<br>• យ៉ាងហោចណាស់មានសមាជិកហ្វេសប៊ុក ចំនួន ២.០០០នាក់ |

# សមាសភាគ ទី៤. ការផ្សព្វផ្សាយទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## ៤.១. សនិទានភាព

លេខាធិការដ្ឋាន គ.ជ.អ.ប រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវមានការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងត្រូវមានទស្សនវិស័យរួមគ្នា។ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសមត្ថភាពក្នុងការពន្យល់អំពីកំណែទម្រង់ដល់សហការីរបស់ខ្លួន និងប្រជាពលរដ្ឋដោយប្រើពាក្យសាមញ្ញៗ។

ឯកសារផអព មានសរសេរនូវពាក្យបច្ចេកទេសជាច្រើន។ ឯកសារផអព ទាំងនោះ ត្រូវបានប្រើប្រាស់ដើម្បីកៀរគរថវិកាពីខាងក្រៅ រៀបចំផែនការ និងត្រួតពិនិត្យការបំពេញការងារ។ ទោះបីជាឯកសារផអពទី២ខ្លីជាងឯកសារផអពដំណាក់កាលទី១ក៏ដោយ ក៏ចាំបាច់ត្រូវមានការកែសម្រួល និងដកស្រង់ ឬសង្ខេបខ្លឹមសារនៃឯកសារនេះឱ្យមានភាពសាមញ្ញ ងាយយល់ និងអាចដឹងច្បាស់លាស់អំពីគោលបំណងដែលចង់សម្រេចបាន។

បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់នូវឯកសារបច្ចេកទេស និង/ឬ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ មន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានតួនាទីសង្ខេបឯកសារទាំងនោះឱ្យមានភាពសាមញ្ញ និងងាយយល់។ ឯកសារដែលបានសង្ខេបទាំងនោះនឹងត្រូវបង្ហាញ ឬផ្សព្វផ្សាយក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល តាមរយៈអ៊ីម៉ែល និងឧបករណ៍ទំនាក់ទំនងផ្សេងៗ។

## ៤.២. គោលបំណង

**សមាសភាគនេះ មានគោលបំណងបង្កើនការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធនិងជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។**

ដើម្បីសម្រេចបាននូវគោលបំណងនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវអនុវត្តតាមដំណាក់កាលចំនួន០៣ ដូចខាងក្រោម៖

១. រៀបចំ និងប្រើប្រាស់ឧបករណ៍ទំនាក់ទំនងឱ្យបានច្បាស់លាស់។

២.ឧបករណ៍ទំនាក់ទំនងទាំងនេះ នឹងត្រូវប្រើប្រាស់ក្នុងព្រឹត្តិការណ៍ប្រចាំថ្ងៃ និងសិក្ខាសាលា។ ឧទាហរណ៍៖ វគ្គបណ្តុះបណ្តាល សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ព្រឹត្តិបត្រព័ត៌មាន តាមរយៈអ៊ីម៉ែល និងឯកសារផ្សេងៗទៀត។

៣. អនុវត្ត និងវាយតម្លៃសកម្មភាពការងារ។

ការដាក់បញ្ចូលឧបករណ៍ ឬសកម្មភាពទំនាក់ទំនងជាយុទ្ធសាស្ត្រទៅក្នុងផែនការសកម្មភាពនិងថវិការបស់ផអ៣ និងទៅក្នុងព្រឹត្តិការណ៍នានា គឺជាកិច្ចការដ៏លំបាក។ ដូច្នេះ ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានត្រូវការសមត្ថភាពផ្នែកបច្ចេកទេសដើម្បីរៀបចំឧបករណ៍ ឬសកម្មភាពទំនាក់ទំនងទាំងនេះ (ឧទាហរណ៍៖ ឧបករណ៍ ឬសកម្មភាពសម្រាប់ពន្យល់អំពីកំណែទម្រង់ដែលមានភាពសាមញ្ញ និងច្បាស់លាស់ )។

## ៤.៣.លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត

**តារាងទី៥៖**

**លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្តសម្រាប់ការផ្សព្វផ្សាយទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

| ល.រ | លទ្ធផលរំពឹងទុក និងសកម្មភាព | ពេលវេលា និង ស្ថាប័នអនុវត្ត |
|---|---|---|
| គោលបំណង៖ ក្រសួង ស្ថាប័នពាក់ព័ន្ធមានការយល់ដឹង និងជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | |
| លទ្ធផលរំពឹងទុក ៤.៣.១ | **រៀបចំ និងអនុវត្តការប្រាស្រ័យទាក់ទង ដែលមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ។**<br>• រៀបចំផែនការសកម្មភាព ដែលបញ្ជាក់ពីឧបករណ៍ទំនាក់ទំនងណាខ្លះនឹងត្រូវដាក់បញ្ចូលក្នុងសិក្ខាសាលា និងព្រឹត្តិការណ៍ផ្សេងទៀតរបស់ ផអព។<br>• កំណត់ និងរៀបចំឱ្យបានជាក់លាក់នូវសម្ភារៈ ឬឧបករណ៍សំខាន់ៗ ដោយផ្អែកលើឧបករណ៍ទំនាក់ទំនង។<br>• កំណត់រឿងជោគជ័យ និងករណីសិក្សា ចុះមូលដ្ឋានដើម្បីសង្កេត ថតរូប និងសរសេរព័ត៌មាន និងអត្ថបទរឿងសម្រាប់ដាក់ក្នុងគេហទំព័រ ឧទាហរណ៍៖ អំពីការអនុវត្តល្អ។<br>• រៀបចំផលិតព្រឹត្តិបត្រព័ត៌មាន សេចក្តីប្រកាសព័ត៌មាន អ៊ីម៉ែល ហើយផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>• បំពេញតម្រូវការព័ត៌មានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាធារណជនផ្សេងទៀតតាមរយៈខ្សែទូរស័ព្ទពិសេស និងយន្តការផ្សេងទៀត។សូមមើលសមាសភាគទី២ក្នុងសេចក្តីណែនាំផ្នែកទី៣អំពីការឆ្លើយតបតាម | • ឆ្នាំ២០១៧<br>• លេខាធិការដ្ឋាន គ.ជ.អ.ប<br>• ថវិកា៖ $0<br>• លទ្ធផល៖ ចំនួន៨០% នៃការស្នើសុំព័ត៌មាន ត្រូវបានឆ្លើយតបឱ្យបានទាន់ពេលវេលា<br>• ឧបករណ៍ទំនាក់ទំនងរបស់ គ.ជ.អ.ប ត្រូវបានប្រើប្រាស់ដោយមន្ត្រីលេខាធិការដ្ឋានគ.ជ.អ.ប (និងមានការស្នើសុំប្រើប្រាស់កាន់តែច្រើនពីរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់យកទៅអនុវត្តនៅមូលដ្ឋាន)។ |

| | | |
|---|---|---|
| | តម្រូវការព័ត៌មាន។<br>• វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តការប្រាស្រ័យទាក់ទងផ្ទៃក្នុង។ | |
| **លទ្ធផលរំពឹងទុក ៤.៣.២** | **រៀបចំ និងអនុវត្តការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ**<br>• ណែនាំឧបករណ៍ទំនាក់ទំនងជាក់លាក់ដល់ក្រសួង ស្ថាប័ន ដូចជា ឯកសារសម្រាប់រៀបចំសារ បញ្ជីទំនាក់ទំនងសំខាន់ៗរបស់លេខាធិការដ្ឋាន គ.ជ.អ.ប រឿងជោគជ័យ សន្លឹកព័ត៌មានខ្លី កម្រងសំណួរដែលសួរញឹកញាប់ជាងគេ។<br>• ផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មាន និងសេចក្ដីប្រកាសព័ត៌មានទៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ។<br>• សាកល្បងបង្កើតប្រព័ន្ធទាក់ទងសម្រាប់មន្ត្រីជាន់ខ្ពស់ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីទាក់ទងជាមួយក្រសួង ស្ថាប័ន។ ឧទាហរណ៍៖ ការផ្តល់ព័ត៌មានសង្ខេបជាលក្ខណៈឯកជន ការជូនដំណឹងអំពីព្រឹត្តិការណ៍ផ្សេងៗ ការអញ្ជើញចូលរួមក្នុងព្រឹត្តិការណ៍របស់ គ.ជ.អ.ប ផ្ញើអត្ថបទព័ត៌មានល្អៗ និងតំណភ្ជាប់ ធ្វើការទាក់ទងជាមួយក្រុមការងារវិភាគ និងអភិវឌ្ឍគោលនយោបាយ ឬរៀបចំកម្មវិធីផ្តល់ព័ត៌មានសង្ខេបដែលមានទ្រង់ទ្រាយធំ។ | • ជាប្រចាំ<br>• លេខាធិការដ្ឋាន គ.ជ.អ.ប និងដៃគូអនុវត្តន៍<br>• ថវិកា៖ $0<br>• លទ្ធផល៖ ក្រសួងស្ថាប័នអាចមានព័ត៌មានគ្រប់គ្រាន់ ក្នុងការនិយាយជាមួយអាជ្ញាធរអំពីកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ |

# សមាសភាគ ទី៥. ការចូលរួមរបស់ប្រជាពលរដ្ឋ

## ៥.១. សន្និទានភាព

ការផ្ទេរមុខងារដល់រដ្ឋបាលក្រុង ស្រុក គឺជាចំណុចសំខាន់ដែលត្រូវធ្វើការផ្សព្វផ្សាយ។ ការប្រើប្រាស់វិធីសាស្ត្រប្រាស្រ័យទាក់ទងខាងក្រៅ អាចជួយជំរុញឱ្យកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការគ្រប់គ្រង ចាត់ចែងការអនុវត្តមុខងារដែលបានផ្ទេរទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព តាមជម្រើសចំនួន០២ ដូចខាងក្រោម៖

- នៅពេលមុខងារត្រូវបានផ្ទេរ ប្រជាពលរដ្ឋត្រូវទទួលបានការយល់ដឹងពីការផ្ទេរមុខងារនេះ។ ក្នុងករណីខ្លះ ការផ្តល់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីការផ្ទេរមុខងារទាំងនេះតាមរយៈអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម (ឧទាហរណ៍៖ ការអប់រំនៅបឋមសិក្សា មណ្ឌលសុខភាព និងរដ្ឋបាលឃុំ)។ ក្រៅពីការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋ មន្ត្រីរដ្ឋាភិបាលត្រូវមានការយល់ដឹងអំពីដំណើរការ មូលហេតុក្នុងការផ្ទេរមុខងារ និងកែប្រែឥរិយាបថក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន។
- ប្រសិនបើក្រសួង ស្ថាប័ន មានភាពស្ទាក់ស្ទើរក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការប្រាស្រ័យទាក់ទង (ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន) អាចជួយជំរុញលើកទឹកចិត្តក្រសួង ស្ថាប័នឱ្យមានការសម្រេចចិត្តក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ ការប្រាស្រ័យទាក់ទងដោយមានការចូលរួមពីប្រជាពលរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំពាក់ព័ន្ធ អាចពន្យល់អំពីផលប្រយោជន៍នានានៃការផ្ទេរមុខងារ

ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យក្រសួង ស្ថាប័នមានជំនឿជឿជាក់ ក្នុងការផ្ទេរមុខងារទាំងនោះ។

### ៤.២. គោលបំណង

ប្រជាពលរដ្ឋមានការយល់ដឹងអំពីការផ្ទេរមុខងារជាក់លាក់ ផលប្រយោជន៍នៃការផ្ទេរមុខងារ និងចូលរួមក្នុងការផ្ដល់យោបល់ត្រឡប់លើការអនុវត្តមុខងារទាំងនោះ ដើម្បីធ្វើឱ្យការផ្ដល់សេវាដល់ពួកគេកាន់តែមានភាពល្អប្រសើរឡើង។

### ៤.៣. អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការផ្តល់សេវា (ការអនុវត្តមុខងារ) ដែលបានផ្ទេរ

#### ៤.៣.១. គោលបំណង

គោលបំណងចម្បង គឺដើម្បីផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលឱ្យដឹងពីការផ្ទេរមុខងារជាក់លាក់នានា និងផលប្រយោជន៍របស់កំណែទម្រង់នេះ។ ក្រុមតស៊ូមតិខាងវិមជ្ឈការ នឹងត្រូវបានបង្កើតឡើងដើម្បីជំរុញឱ្យប្រជាពលរដ្ឋចូលរួមផ្ដល់យោបល់ត្រឡប់។ យុទ្ធនាការនេះមានគោលបំណង[3]៖

- យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន ១០០.០០០នាក់ យល់ដឹងអំពីការផ្ទេរមុខងារ។
- យ៉ាងហោចណាស់មានអង្គការសង្គមស៊ីវិលចំនួន០៥ ចូលរួមក្នុងយុទ្ធនាការ។

#### ៤.៣.២ ពេលវេលា

ការកំណត់ពេលវេលាធ្វើយុទ្ធនាការ គឺជាគន្លឹះសំខាន់ដើម្បីទទួលបានជោគជ័យ។ ពេលវេលាដែលសមស្របសម្រាប់អនុវត្តយុទ្ធនាការផ្សព្វផ្សាយ គឺធ្វើឡើងស្របពេល

---

[3] ការត្រួតពិនិត្យ និងវាយតម្លៃធ្វើឡើងដោយផ្ដោតលើបរិមាណដែលបានកំណត់។

នៃការផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាទូទៅ ប្រជាពលរដ្ឋតែងតែចាប់អារម្មណ៍លើសកម្មភាពជាក់ស្តែងជាជាងទ្រឹស្តី។ ការកំណត់ពេលវេលាសម្រាប់ធ្វើយុទ្ធនាការតាមទូរទស្សន៍ គួរធ្វើឡើងនៅពេលដែលមុខងារត្រូវបានផ្ទេរទៅដល់រដ្ឋបាលក្រុង ស្រុក ភាគច្រើន។

### ៤.៣.៣ ក្រុមគោលដៅ

ក្រុមគោលដៅមានផ្សេងៗគ្នាអាស្រ័យតាមមុខងារដែលត្រូវផ្ទេរ។ ឧទាហរណ៍៖ ក្រុមគោលដៅអាចជា៖

- អ្នកទទួលផលពីសេវាដែលបានធ្វើវិមជ្ឈការ ឧទាហរណ៍៖ មាតាបិតា និងក្រុមគ្រួសារដែលមានកូនរៀននៅសាលាបឋមសិក្សា ឬកូនដែលមានអាយុជិតចូលរៀននៅសាលាបឋមសិក្សា នៅអំឡុងពេលនៃការផ្ទេរមុខងារអប់រំនៅសាលាបឋមសិក្សា។ ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់ ឬមានបំណងប្រើប្រាស់សេវាសុខភាពនៅមណ្ឌលសុខភាព ដូចជាស្ត្រីមានផ្ទៃពោះ។
- ក្រុមប្រឹក្សាដែលជាតំណាងរបស់ប្រជាពលរដ្ឋ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាក្រុមគោលដៅបន្ទាប់។

### ៤.៣.៤ ចំណុចសំខាន់ដែលត្រូវបង្ហាញ

គួរមានឧទាហរណ៍ជាក់លាក់ដែលបង្ហាញអំពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា។ ឧទាហរណ៍៖

- បច្ចុប្បន្ននេះ រដ្ឋបាលមូលដ្ឋាន គឺជាអ្នកគ្រប់គ្រងសាលាបឋមសិក្សា។ ក្រុមប្រឹក្សាជាអ្នកទទួលខុសត្រូវចំពោះការទទួលបានការសិក្សា ដោយ

មិនបង់ប្រាក់ ការគ្រប់គ្រងថវិកា និងការបំពេញតួនាទី ភារកិច្ចរបស់គ្រូបង្រៀន។

- គួរយកចិត្តទុកដាក់កំណត់ចំណុចសំខាន់ៗ ដែលមិនមែនជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ដើម្បីជៀសវាងប្រជាពលរដ្ឋមានការរំពឹងទុកខ្ពស់ពីក្រុមប្រឹក្សា។

### ៥.៣.៥ បណ្តាញផ្សព្វផ្សាយ

ការប្រើប្រាស់បណ្តាញផ្សព្វផ្សាយចម្រុះ គួរធ្វើឱ្យអស់លទ្ធភាព។ ត្រូវរកដៃគូជួយក្នុងការរៀបចំយុទ្ធនាការ។ គួរពិចារណាជម្រើសខាងក្រោម៖

**តារាងទី៦៖**
**យុទ្ធនាការផ្សព្វផ្សាយដែលមានសក្តានុពលក្នុងការធ្វើឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងផលប្រយោជន៍របស់ប្រព័ន្ធផ្សព្វផ្សាយ**

| ប្រព័ន្ធផ្សព្វផ្សាយ | ផលប្រយោជន៍ | ជាតុសំខាន់ៗ |
|---|---|---|
| ទូរទស្សន៍ | ទៅដល់ក្រុមគោលដៅបានទូលំទូលាយក្នុងពេលតែមួយ | • **ស្ពត (Spots)** ទូរទស្សន៍ដែលមានសារសាមញ្ញៗ<br>• ផ្សាយផ្ទាល់ក្នុងកម្មវិធីរាត្រីថ្ងៃសៅរ៍ (កម្មវិធីកំប្លែង)<br>• ព័ត៌មាន (រួមបញ្ចូលការសម្ភាសតាមប្រព័ន្ធផ្សព្វផ្សាយ)។ |
| វិទ្យុ | ទៅដល់ក្រុមគោលដៅបានទូលំទូលាយ អាចសន្ទនាគ្នា និងអាចឆ្លើយសំណួរប្រជាពលរដ្ឋបាន | • វិទ្យុមូលដ្ឋាន ឬវិទ្យុសហគមន៍ (យោងតាមទិន្នន័យអ្នកស្តាប់ និងជំនាញផលិតកម្មវិធីវិទ្យុ)។<br>• **ស្ពត**(Spots) **វិទ្យុ** ដែលមាន |

| | | |
|---|---|---|
| | | សារសាមញ្ញៗដែលរៀបចំរួចជាស្រេចនូវពាក្យពេចន៍សម្រាប់និយាយ។<br>• កម្មវិធីសន្ទនាតាមវិទ្យុជាមួយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ និង/ឬល្ខោននិយាយ។ |
| ឧគ្ឃោសនសព្ទ | ទៅដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ | ប្រើប្រាស់សារសាមញ្ញៗដែលមានស្រាប់ សម្រាប់ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ អំពីសកម្មភាពជាក្រុម កិច្ចប្រជុំ កម្មវិធីវិទ្យុ ស្តង់ផ្តល់ព័ត៌មាន។ល។ |
| ខិត្តប័ណ្ណ | ពន្យល់ពីប្រយោជន៍ជាក់លាក់ និងវិធីសាស្ត្រចូលរួម | រូបភាព និងសារដែលរៀបចំតាមមុខងារជាក់លាក់ដែលបានផ្ទេរ។ |
| កិច្ចប្រជុំសហគមន៍ | មានប្រយោជន៍សម្រាប់ផ្លាស់ប្តូរព័ត៌មានជាក់លាក់ជាមួយក្រុមសហគមន៍តូចៗនៅមូលដ្ឋាន | យុទ្ធនាការសាកល្បងដើម្បីដឹងថា សារមួយណាមានប្រសិទ្ធភាព មានដូចជាប្រជុំនៅតាមភូមិ សកម្មភាពធ្វើការជាក្រុម ក្លឹបអ្នកស្តាប់។ |
| សកម្មភាពតាមរយៈស្តង់ផ្តល់ព័ត៌មាន | ទៅដល់មូលដ្ឋាន | ធ្វើស្របពេលជាមួយនឹងព្រឹត្តិការណ៍តាមមូលដ្ឋាននិងពិធីបុណ្យផ្សេងៗ រួមទាំងផ្ទាំងព័ត៌មាន ខិត្តប័ណ្ណ ល្បែង កម្សាន្ត។ |
| ដាក់បញ្ចូលជាមួយសកម្មភាពការងារ | ចូលរួមចំណែកផ្សព្វផ្សាយអំពីកំណែទម្រង់វិមជ្ឈការ និង | • កិច្ចប្រជុំរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ |

| | | |
|---|---|---|
| គណនេយ្យភាពសង្គម | វិសហមជ្ឈការតាមរយៈកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ | • ការផ្សព្វផ្សាយពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ<br>• សកម្មភាពពង្រឹងសមត្ថភាពផ្សេងៗ។ |
| បណ្តាញទំនាក់ទំនងសង្គម | អាចទៅដល់ក្រុមគោលដៅជាយុវជនបានយ៉ាងរហ័ស | ដាក់បញ្ចូលក្នុងសមាសភាគបណ្តាញទំនាក់ទំនងសង្គម។ |

ក្នុងការអនុវត្តយុទ្ធនាការនេះ នឹងត្រូវការសម្ភារៈគាំទ្រជាច្រើនដូចជា សារ ឬព័ត៌មាននានាដែលបានកំណត់ (ដើម្បីជានាសង្គតិភាព) ប្រធានបទសម្រាប់ពិភាក្សា និងខិត្តប័ណ្ណ (ឧទាហរណ៍៖ សម្រាប់ប្រើប្រាស់ដោយក្រុមប្រឹក្សា និងមន្ត្រីថ្នាក់មូលដ្ឋាន) ឯកសារសម្រាប់អ្នកសារព័ត៌មាន សេចក្តីប្រកាសព័ត៌មាន និងឧបករណ៍ទំនាក់ទំនងផ្ទៃក្នុង (ជូនដំណឹងដល់អ្នកពាក់ព័ន្ធសំខាន់ៗអំពីយុទ្ធនាការផ្សព្វផ្សាយ)។

## ៥.៤. អនុវត្តការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រដើម្បីជំរុញការផ្ទេរមុខងារ

ការទំនាក់ទំនងអាចត្រូវបានប្រើប្រាស់ដើម្បីជំរុញឱ្យមានការផ្ទេរមុខងារ។ ការទំនាក់ទំនងជាយុទ្ធសាស្ត្រអាចអនុវត្តដូចខាងក្រោម៖

- ប្រជាពលរដ្ឋ ផ្តល់ការគាំទ្រកាន់តែច្រើនដើម្បីឱ្យមានការផ្ទេរមុខងារ។
- រដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញអំពីផលប្រយោជន៍ជាសក្តានុពលនៃការផ្ទេរមុខងារ។
- ក្រសួង ស្ថាប័នដែលបានធ្វើការផ្ទេរមុខងារអាចបង្ហាញពីផលប្រយោជន៍នៃកំណែទម្រង់។

- ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលអាចតស៊ូមតិឱ្យមានការផ្ទេរមុខងារបន្ថែម។

## ៤.៤.លទ្ធផលរំពឹងទុក សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្ត

**តារាងទី៧៖**

**លទ្ធផលរំពឹងទុកសំខាន់ៗ សកម្មភាព ពេលវេលា និងស្ថាប័នអនុវត្តសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ**

| ល.រ | លទ្ធផលរំពឹងទុក និងសកម្មភាព | ពេលវេលា និង ស្ថាប័នអនុវត្ត |
|---|---|---|
| គោលបំណង៖ ប្រជាពលរដ្ឋមានការយល់ដឹងអំពីផលប្រយោជន៍ នៃការផ្ទេរមុខងារជាក់លាក់ និងចូលរួមក្នុងយន្តការផ្តល់យោបល់ត្រឡប់ដើម្បីធ្វើឱ្យការផ្តល់សេវាដល់ពួកគេប្រសើរឡើងៗ<br>លទ្ធផល៖<br>• យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន ១០០.000នាក់ មានការយល់ដឹងអំពីការផ្ទេរមុខងារ ឬសេវារដ្ឋបាលថ្នាក់ក្រោមជាតិសំខាន់ៗ។<br>• យ៉ាងហោចណាស់មានក្រសួងចំនួន០២ ធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈជាវិជ្ជមានអំពីការផ្ទេរមុខងារ។ | | |

| | | |
|---|---|---|
| **លទ្ធផលរំពឹងទុក ៥.៥.១** | **អនុវត្តយុទ្ធនាការផ្សព្វផ្សាយសង្គមដើម្បីលើកកម្ពស់ការផ្ទេរមុខងារ**<br>• រៀបចំល័ក្ខខ័ណ្ឌការងារ និងជួលទីប្រឹក្សារយៈពេលខ្លី ឬធ្វើការជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងការអនុវត្តយុទ្ធនាការលើកកម្ពស់សង្គម។<br>• កំណត់គោលបំណង និងគោលដៅជាក់លាក់។<br>• កំណត់ក្រុមគោលដៅ និងសារសំខាន់ៗ។<br>• កំណត់ប្រព័ន្ធផ្សព្វផ្សាយ (សូមមើលតារាង) ដែលអាចមានប្រសិទ្ធភាពខ្ពស់បំផុត។<br>• ផលិតសម្ភារៈ ដោយមានការចូលរួមជាមតិយោបល់របស់អ្នកប្រើប្រាស់ដើម្បីធានាថាសម្ភារៈទាំងនោះអាចជឿជាក់បាន និងទាក់ទាញការចាប់អារម្មណ៍។<br>• វាយតម្លៃប្រសិទ្ធភាពនៃយុទ្ធនាការ។ | • ខែធ្នូ ឆ្នាំ២០១៧ អនុវត្តរាល់ឆ្នាំ។<br>• លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ឬក្រសួង ស្ថាប័នអនុវត្តផ្សេងទៀត។<br>• ថវិកា៖ ប្រមាណ ៥០.០០០ទៅ ៤០០.០០០ ដុល្លារ |
| **លទ្ធផលរំពឹងទុក ៥.៥.២** | **អនុវត្តយុទ្ធនាការដើម្បីជំរុញឱ្យក្រសួង ស្ថាប័ន ផ្ទេរមុខងារ**<br>• កំណត់សេវា និង ឥរិយាបថដែលមានលក្ខណៈអភិបាលកិច្ចល្អដែលត្រូវកែប្រែ។<br>• ប៉ាន់ប្រមាណវិធីសាស្រ្តផ្សេងៗដែលអាចអនុវត្តបាន និងរួមបញ្ចូលក្រុមគោលដៅអាទិភាពដូចជាប្រជាពលរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ថ្នាក់ដឹកនាំ អ្នករៀបចំគោលនយោបាយ។ល។<br>• រៀបចំ និងអនុវត្តយុទ្ធសាស្រ្ត។ | • ឆ្នាំ ២០១៨<br>• លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ក្រសួងស្ថាប័នអនុវត្តផ្សេងទៀត។<br>• ថវិកា៖ប្រហែល ២០.០០០-១០០.០០០ដុល្លារ ទៅតាមទំហំនៃយុទ្ធនាការ។ |

# ៦. ផែនការសកម្មភាព និងថវិកា

## ខាងក្រោមនេះគឺជាផែនការសកម្មភាព និងថវិកាសង្ខេប

### តារាងទី៨៖

### ផែនការសកម្មភាពប្រាស្រ័យទាក់ទងសង្ខេប

| គោលបំណង/លទ្ធផល | ២០១៧ | | ២០១៨ | | | | ២០១៩ | | | | ថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រី ៣ | ត្រី ៤ | ត្រី ១ | ត្រី ២ | ត្រី ៣ | ត្រី ៤ | ត្រី ១ | ត្រី ២ | ត្រី ៣ | ត្រី ៤ | |
| ១. ការបង្កើតឧបករណ៍ទំនាក់ទំនងសំខាន់ៗដែលអាចប្រើប្រាស់ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងសមស្របទៅតាមស្ថានភាពជាក់ស្តែង | | | | | | | | | | | |
| ១.១ ឧបករណ៍ទំនាក់ទំនង ដោយមានឈ្មោះ/រូបសញ្ញាសម្គាល់ គ.ជ.អ.ប ត្រូវបានរៀបចំបង្កើត | ■ | ■ | ■ | | | | ■ | | | | ២០.០០០ដុល្លារ |
| ១.២ សេចក្តីណែនាំសម្រាប់ការប្រាស្រ័យទាក់ទងរបស់អង្គភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នអនុវត្តផអព ត្រូវបានរៀបចំបង្កើត | ■ | ■ | ■ | | | | | | | | $0 |
| ១.៣ បង្កើតបណ្ណុំរូបភាព និងក្រាហ្វិកព័ត៌មានដែលមានគុណ | | | ■ | ■ | | | ■ | | | | ១.៥០០០ដុល្លារ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ភាពខ្ពស់ | | | | | | | | | | |
| ១.៤ កែលំអគេហទំព័រ គ.ជ.អ.ប ឱ្យប្រសើរឡើង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ៤.០០០ដុល្លា |
| | | | | | | | | | | | |
| ២. ពង្រឹងសមត្ថភាពការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីឱ្យការិយាល័យនេះអាចផ្តួចផ្តើមអនុវត្តការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព | | | | | | | | | | | |
| ២.១ កែសម្រួលតួនាទី ភារកិច្ចការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានឡើងវិញ និងបង្កើនចំនួនបុគ្គលិក ដើម្បីទទួលបានជំនាញបន្ថែមទៀត | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | $២៤.០០០/ឆ្នាំ |
| ២.២ បង្កើតប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដល់ក្រុមគោលដៅ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | |
| ២.៣ បង្កើតភាពជាដៃគូយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាព និងអនុវត្តសកម្មភាពប្រាស្រ័យទាក់ទងរួម | | | ■ | | | | ■ | | | | |
| ៣. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើបជួយបង្កើនការគាំទ្រ និងពង្រឹងការយល់ដឹងអំពីកំណែទម្រង់ | | | | | | | | | | | |
| ៣.១ បង្កើត និងអនុវត្តកម្មវិធីប្រព័ន្ធផ្សព្វផ្សាយ | ■ | ■ | ■ | | | | | | | | |
| ៣.២ បង្កើត និងប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដែល | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ២០.០០០ដុល្លារ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងមន្ត្រីរាជរដ្ឋាភិបាល | | | | | | | | | | | |
| ៤. ក្រសួង ស្ថាប័នពាក់ព័ន្ធមានការយល់ដឹង និងជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | | | | | | | | | | |
| ៤.១ រៀបចំ និងអនុវត្តការប្រាស្រ័យទាក់ទង ដែលមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | |
| ៤.២ រៀបចំ និងអនុវត្តការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ | | | | | | | | | | | |
| ៥. ប្រជាពលរដ្ឋមានការយល់ដឹងអំពីផលប្រយោជន៍ នៃការផ្ទេរមុខងារជាក់លាក់ និងចូលរួមក្នុងយន្តការផ្តល់យោបល់ត្រឡប់ដើម្បីធ្វើឱ្យការផ្តល់សេវាដល់ពួកគេប្រសើរឡើង | | | | | | | | | | | |
| ៥.១ អនុវត្តយុទ្ធនាការផ្សព្វផ្សាយសង្គមដើម្បីលើកកម្ពស់ការផ្ទេរមុខងារ[4] | | | | | ■ | ■ | ■ | ■ | ■ | ■ | ៥០.០០០-៤០០.០០០ដុល្លារ |
| ៥.២ អនុវត្តយុទ្ធនាការដើម្បីជំរុញឱ្យក្រសួង ស្ថាប័នផ្ទេរមុខងារ | | | | | | | ■ | ■ | ■ | ■ | ២០.០០០-១០០.០០០ដុល្លារ |

[4] ថវិកានៃយុទ្ធនាការផ្សព្វផ្សាយក្នុងសង្គមពឹងផ្អែកយ៉ាងខ្លាំងលើវិសាលភាពនៃយុទ្ធនាការនិងប្រព័ន្ធផ្សព្វផ្សាយដែលត្រូវប្រើ( ឧទាហរណ៍ ទូរទស្សន៍ វិទ្យុ )។ ដូចបង្ហាញក្នុងតួលេខនៃឯកសារផអ៣ទី២។

គាំទ្រដោយ

Sida

Swiss Agency for Development
and Cooperation SDC